# សេចក្ដីប្រកាសព័ត៌មានរួមរបស់ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និងអង្គការសុខភាពពិភពលោក
# ករណីវិជ្ជមាននៃជម្ងឺផ្ដាសាយ A (H1N1) ជាលើកដំបូងនៅប្រទេសកម្ពុជា

ភ្នំពេញ ថ្ងៃពុធ ទី ២៤ មិថុនា ឆ្នាំ ២០០៩, ម៉ោង ១១ ព្រឹក

កាលពីថ្ងៃអង្គារ ទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ មជ្ឈមណ្ឌលជាតិកម្ពុជាសម្រាប់ជម្ងឺផ្ដាសាយបាន បញ្ជាក់ថា មានករណីវិជ្ជមាននៃជម្ងឺផ្ដាសាយ A (H1N1) ជាលើកដំបូងនៅប្រទេសកម្ពុជា ។ បុគ្គលដែលមានផ្ទុកមេរោគជំងឺនេះ គឺជានារីពលរដ្ឋអាមេរិកមានអាយុ១៦ឆ្នាំ ដែលជាសមាជិកក្រុមនិស្សិតមួយក្រុមមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ហើយបានមកដល់រាជធានីភ្នំពេញកាលពីថ្ងៃ សុក្រ ទី ១៩ មិថុនា កន្លង ទៅនេះ ។ នាងមានរោគសញ្ញាជំងឺនេះ មួយថ្ងៃបន្ទាប់ពីការមកដល់របស់នាង ហើយបន្ទាប់មកក៏បានស្វែងរកការថែទាំនៅគ្លីនិកឯកជនមួយ កាលពីថ្ងៃច័ន្ទ ទី ២២ មិថុនា ។ ដោយសំអាងលើសញ្ញាគ្លីនិក និង ប្រវត្តិនៃការធ្វើដំណើររបស់នាង គ្លីនិកឯកជនមានការព្រួយបារម្ភថា អ្នកជម្ងឺមានឆ្លងវីរុសផ្ដាសាយ A (H1N1) ។ វត្ថុវិភាគត្រូវបានគេយកពីអ្នកជំងឺ ហើយបញ្ជូនទៅ មជ្ឈមណ្ឌលជាតិសម្រាប់ធ្វើតេស្តផ្ដាសាយ ។ លទ្ធផលវិជ្ជមានត្រូវបានបញ្ជាក់ឱ្យដឹងកាលពីថ្ងៃអង្គារ ទី ២៣ មិថុនា ដោយប្រើប្រាស់តេស្តដែលបានរៀបចំឡើងជាពិសេសសម្រាប់រកវីរុសផ្ដាសាយ A (H1N1) ។ អ្នកជម្ងឺត្រូវបានរក្សាទុកដោយឡែកក្នុងអំឡុងពេលនៃការធ្វើតេស្ត ។

ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល មានប្រសាសន៍ថា "ការមកដល់ជាយថាហេតុនៃវីរុសនេះត្រូវបានគេរំពឹងទុករួចមកហើយនៅពេលដែលវីរុសនេះកំពុង ធ្វើចរាចរជាសកល ។ យើងមានប្រព័ន្ធនានាដែលយើងបានត្រៀមរួចហើយនោះ ឥឡូវនេះបានដំណើរការក្នុងការរកឃើញករណីមួយនេះហើយនិងបានដាក់ឱ្យនៅដោយឡែក ។

ដោយអនុលោមតាមការណែនាំថ្នាក់ជាតិកម្ពុជាស្ដីអំពីចំណាត់ការជាមួយការរាតត្បាតរោគផ្ដាសាយជាសកល អ្នកជម្ងឺកំពុងត្រូវបានរក្សាទុកដោយឡែកនៅមន្ទីរថែទាំសុខភាពមួយ ។ នាងកំពុងស្ថិត

ក្នុងលក្ខណៈសុខភាពមាំទាំ ហើយមានភាពប្រសើរឡើងវិញដោយមិនមានសភាពស្មុគ្រស្មាញនានាមកញាំញីទេ ។ ដោយអនុលោមនិយាមវិធានការបង្ការ សមាជិកដទៃទៀតនៃក្រុមរបស់នាងបានស្ថិតក្នុងការតាមដានដោយស្ម័គ្រចិត្តផងដែរដើម្បីតាមរកមើលសញ្ញាឆ្លងមេរោគនេះ ។

មន្ត្រីនានានៃក្រសួងសុខាភិបាល និង អង្គការសុខភាពពិភពលោកបានប្រជុំគ្នាកាល ពីយប់មិញ ដើម្បីចែករំលែកព័ត៌មានគ្នា និង អនុវត្តផែនការជាតិសម្រាប់ជម្ងឺផ្តាសាយ ។ ក្នុងកិច្ចសហការជាមួយអង្គការសុខភាពពិភពលោក ក្រសួងសុខាភិបាលនឹងបន្តតាមដានស្ថានភាពនេះយ៉ាងជិតដិត ហើយជូនព័ត៌មានដល់សាធារណជនឱ្យបានជាប់លាប់ ។

<u>ការផ្តល់ដំបូន្មានសុខភាពសាធារណៈ</u>

ក្រសួងសុខាភិបាល និង អង្គការសុខភាពពិភពលោក សូមធ្វើការណែនាំដល់សាធារណៈជន ថាវិធីដែលមានប្រសិទ្ធភាពបំផុតក្នុងការការពារការឆ្លងវីរុស ផ្តាសាយ A (H1N1) គឺ បន្តអនុវត្តន៍អនាម័យផ្ទាល់ខ្លួនស្អាតជានិច្ច ជាពិសេសគឺ :

- ខ្ទប់មាត់ និងច្រមុះ ដោយក្រដាសជូតមាត់ពេលក្អក និងកណ្តាស់
- លាងដៃ ទៀងទាត់ជាមួយសាប៊ូ ( ជាពិសេសបន្ទាប់ពីក្អក និងកណ្តាស់ និងមុនពេលបរិភោគអាហារ)
- សូមកុំខាក ស្តោះនៅទីសាធារណៈ

រោគសញ្ញានៃ ផ្តាសាយ A (H1N1) រួមមានការក្តៅខ្លួនលើសពី ៣៨ អង្សាសេ ក្អក កណ្តាស់ ក្អួត និងរាគរូស ។

អ្នកទាំងឡាយណា ដែលមានរោគសញ្ញាទាំងនេះ គួរនៅផ្ទះ, ចៀសវាងទីកន្លែងមានមនុស្សច្រើនកុះករ និងទំនាក់ទំនងលេខទូរសព្ទ័សំរាប់ជំងឺផ្តាសាយនៃក្រសួងសុខាភិបាលដែលមានលេខៈ ០១២ ៤៨៨ ៩៨១ ឬ០៨៩ ៦៦៩ ៩៦៧ ។ អ្នកទាំងឡាយណា ដែលមានរោគសញ្ញាទាំងនេះ ហើយមានការលំបាកក្នុងការដកដង្ហើម គួរធ្វើការរាយការណ៍ទៅកាន់គ្រឹះស្ថានសុខាភិបាលដែលនៅជិតបំផុត ដើម្បីស្វែងរកការផ្តល់ដំបូន្មានបន្ថែម ។

ក្នុងពេលបច្ចុប្បន្ននេះ មិនទាន់មានវ៉ាក់សាំងការពារជំងឺផ្តាសាយ A (H1N1) នេះនៅឡើយទេ និង អ្នកជំងឺភាគច្រើនក៏ពុំចាំបាច់ត្រូវការថ្នាំប្រឆាំងនឹងវីរុសដែរ ។ ការព្យាបាលរួមមានការបរិភោគភេសជ្ជៈអោយបានច្រើន សំរាក និង លេបថ្នាំ ប៉ារ៉ាសេតាមុល ។

<u>សេចក្តីពន្យល់អំពីសារវតាះ</u>

ជម្ងឺ A (H1N1) រឺហៅថាវីរុសរីករាលដាល A H1N1 ២០០៩ ចាប់ផ្តើមរីករាលដាលនៅខែ មេសា ២០០៩ ។ ចាប់ពី ថ្ងៃ ២២ មិថុនា ២០០៩ មានច្រើនជាង ៩០ប្រទេស ត្រូវបានរាយការណ៍ថាមាន វត្តមានវីរុសនេះ និង ប៉ះពាល់ដល់ប្រជាជន ៥២១៦០ នាក់ និង បង្កអោយស្លាប់ ២៣១ នាក់ ។

សំរាប់ ពត៌មានបន្ថែមសូមទំនាក់ទំនង:

ក្រសួងសុខាភិបាល

លោកវេជ្ជបណ្ឌិត សុខ ទូច ទូរសព្ទ័ ៨៥៥ ១២ ៨៥៦ ៨៤៨

លោកវេជ្ជបណ្ឌិត លី សូវ៉ាន់ ទូរសព្ទ័ ៨៥៥ ១២ ៨២៥ ៤២៤

អង្គការសុខភាពពិភពលោក

លោកវេជ្ជបណ្ឌិត ម៉ៃឃើល អូលែរី ទូរសព្ទ័ ៨៥៥ ២៣ ២១៦ ៦១០